2466
16-6-2005

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០២...បប.....

# បទបញ្ជា
## ស្តីពី
## ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

********

អនុលោមតាមមាត្រា ៩ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ ឧស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ បទបញ្ជាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លេខ ៣០ បប ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៧ តម្រូវឱ្យគ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និង ខេត្ត-ក្រុង អនុវត្ត និង ធានានូវការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ឱ្យបានគង់មាំ គង់វង្ស និង ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និង តាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន ។ បទបញ្ជាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លេខ ៣០ បប នេះ គ្របដណ្តប់លើសម្បទាន ការជួល លក់ ផ្ទេរ និង ឯកជនភាវូបនីយកម្ម ព្រមទាំងការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅក្រោមក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន ខេត្ត-ក្រុង និង ឃុំ- សង្កាត់ ឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលដាក់ចេញនូវបទបញ្ជាដូចតទៅ ÷

### ១- គោលការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ក- ចាប់ពីពេលនេះតទៅ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈទាំងឡាយ ដូចមានចែងក្នុង ច្បាប់ភូមិបាល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ មិនអាចត្រូវបានលក់ ផ្ទេរ ជួល ឬផ្តល់ឱ្យជាសម្បទានផ្សេងៗបានឡើយ លុះត្រាតែទ្រព្យសម្បត្តិសាធារណៈទាំងនោះ ត្រូវបានកំណត់ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង របស់នីតិបុគ្គសាធារណៈ ស្របតាមបទប្បញ្ញត្តិច្បាប់ ។